# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូប្រសូតនៅចំការទៀង
# ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៨
*ឲ្យជីវិតរបស់យើងទៅជារោងព្រះយេស៊ូប្រសូត*

| |
|---|
| អត្ថបទទី១៖ មីក ៥,១-៤ក<br>ដំណឹងល្អ៖ លក ១,៣៩-៤៥ |

បងប្អូនជាទីស្រឡាញ់!

យើងបានស្តាប់សម្លេងរបស់ទេវទូតទាំងឡាយ "**សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត សូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គបានសេចក្តីសុខសាន្ត**"។ ជាដំណឹងល្អដែលយើងស្តាប់យប់នេះ រួមជាមួយទេវទូតទាំងអស់យើងទទួលស្គាល់ថាព្រះកុមារយេស៊ូដែលប្រសូតហើយ ណែនាំឲ្យមនុស្សទាំងអស់ពោរពេញដោយសេចក្តីសុខសាន្ត និងអំណរសប្បាយ ដោយសារយើងមើលឃើញជាក់ស្តែងយប់នេះព្រះជាម្ចាស់ចាប់កំណើតជាមនុស្ស។ យើងបានរៀបចំព្រះវិហារ ផ្កា ភ្លើង... ដើម្បីស្វាគមន៍បងប្អូន ជាពិសេសដើម្បីស្វាគមន៍ព្រះកុមារយេស៊ូ និងដើម្បីបង្ហាញអំពីអំណរសប្បាយដែលយើងមានយប់នេះ។ ឥឡូវនេះ យើងទាំងអស់គ្នាយើងបានឆ្លងទន្លេអស់ហើយ ដូច្នេះព្រះសហគមន៍ពោរពេញដោយអំណរសប្បាយ។ នៅក្នុងរដូវរង់ចាំ យើងបានភ័យផង អរផង ត្រៀមខ្លួនផង យើងបានរៀបចំចិត្តគំនិតហើយ យប់នេះយើងមានអំណរសប្បាយ ដោយសារព្រះយេស៊ូប្រសូតហើយ។ ថ្ងៃនេះជាថ្ងៃអស្ចារ្យ ណែនាំឲ្យយើងរួមជាមួយទេវទូតទាំងអស់ យើងបង្ហាញអំណរសប្បាយរបស់យើងដល់បងប្អូនទាំងអស់។

ឆ្នាំនេះ ២០ឆ្នាំដែលខ្ញុំបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ និង២០ឆ្នាំដែលខ្ញុំទទួលបេសកកម្មនៅប្រទេសកម្ពុជា។ នៅឆ្នាំ២០០១ បុណ្យព្រះយេស៊ូប្រសូតជាមួយកូនក្មេងប្រហែល ២០នាក់ និងបងប្អូនដែលចូលរួមមិនដល់១០០នាក់ផង។ នៅឆ្នាំ២០០៣ យើងបានសម្តែងរឿងព្រះយេស៊ូប្រសូតជាមួយក្រុមយុវជនយើង មានប្រជាជនដែលមកមើលប្រហែល២០០នាក់ជាងនេះជាជីវិតរបស់យើង២០ឆ្នាំមុន។

ខ្ញុំទៅកំពត នៅឆ្នាំ២០០២ មានតែបីនាក់ខ្ញុំ លោកឪពុកលី និងម៉ន ពេលមានបុណ្យព្រះយេស៊ូប្រសូតគ្មានមនុស្សទេ។ ប៉ុន្តែ២០ឆ្នាំក្រោយមក នៅចំការទៀងបុណ្យព្រះយេស៊ូប្រសូតជាមួយកូនក្មេងយើងមានជិត៣០០០នាក់ និងយប់នេះប្រហែលមានជាង៣០០០នាក់ ដែលចូលរួមអំណរសប្បាយជាមួយយើង។ នៅកំពតក៏ដូចគ្នា យើងមានរាប់រយនាក់ដែលមកចូលរួមជាមួយយើង។ សាលាកាតូលិកគ្រប់កម្រិតសិក្សា ដែលយើងមាននៅក្នុងស្រុកត្រាំកក់ ឆ្នាំនេះ

សរុបមានសិស្ស-និស្សិត ១១០០នាក់ ដោយចាប់ផ្តើមពី៣០នាក់កាល២០ឆ្នាំមុន។ គ្រីស្តបរិស័ទចាប់ផ្តើមពីលោកគ្រូ ជៀង ម្នាក់ ឥឡូវយើងមានគ្រីស្តបរិស័ទរាប់រយនាក់ ទាំង៨កន្លែងដែលយើងមាននៅក្នុងខេត្តតាកែវ។ យើងបានបង្កើតទំនាក់ទំនងជាមួយពុទ្ធសាសនា រៀងរាល់ឆ្នាំពេលបុណ្យព្រះយេស៊ូប្រសូត មានចៅអធិការ និងគណកម្មការវត្ត មកចូលរួមអបអរសាទរព្រះសហគមន៍យើង។ ភូមិសុខសាន្ត យើងបានចាប់ផ្តើមជាមួយគ្រួសារដែលរស់នៅជាមួយមេរោគអេដស៍ប៉ុន្មានគ្រួសារនៅភ្នំវល្លិ៍ ពេលនេះយើងមានមហាគ្រួសារ៤៥០នាក់ ទាំងឪពុកម្តាយ ទាំងកូនៗ ទាំងអ្នកពិការទាំងអ្នកជំងឺអេដស៍។

អ្វីដែលយើងបានសាបព្រោះ ២០ឆ្នាំក្រោយមកយើងបានទទួលផលយ៉ាងច្រើន ថ្ងៃនេះជាពេលវេលាមួយដើម្បីនឹកឃើញអ្វីៗទាំងអស់ដែលយើងមើលឃើញ មកពីព្រះយេស៊ូដែលប្រសូតនៅទីនេះ។ នៅរាត្រីព្រះយេស៊ូប្រសូតនេះ ព្រះសហគមន៍របស់យើងមានសមត្ថភាពប្រកាសដំណឹងល្អនៅក្នុងរបៀបថ្មី តាមរយៈរោងព្រះយេស៊ូប្រសូត តាមរយៈភ្លើង តាមរយៈការតុបតែងតាមរយៈសិល្បៈ...យើងដឹងថាអ្វីៗទាំងអស់មកពីព្រះយេស៊ូ។ អំណរសប្បាយ សេចក្តីសុខរបស់ខ្ញុំ គឺឃើញស្នាដៃរបស់បងប្អូនទាំងអស់រីកចម្រើន អ្វីៗទាំងអស់ដែលអាចមាន កម្លាំងដែលអាចមាន ទស្សនៈដែលអាចមាន... ដោយសារព្រះយេស៊ូ។ ឥតមានព្រះយេស៊ូ អ្វីៗដែលយើងធ្វើមិនអាចទៅមុខបានទេ មិនបានចូលនៅក្នុងដួងចិត្តរបស់ប្រជាជន។ ព្រះបន្ទូលបានធ្វើដំណើរក្នុងពិភពលោកពីដើម គឺចេញពីភូមិមួយទៅភូមិមួយយើងបានប្រកាសដំណឹងល្អទូទាំងពិភពលោកទាំងមូល។ ដូចគ្នាចេញពីភូមិចំការទៀងដ៏តូចនេះ យើងបានទៅប្រកាសដំណឹងល្អដល់៨កន្លែងនៅក្នុងខេត្តតាកែវ ដើម្បីឲ្យមនុស្សលោករស់នៅក្នុងសេចក្តីសុខ និងបង្កើតមហាគ្រួសារ។

មានបងប្អូនមួយចំនួនដែលបានស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ និងសុខចិត្តដើរតាមព្រះអង្គណែនាំឲ្យយើងបានឃើញជាក់ស្តែងជីវិតដែលយើងបានទទួល និងបន្តណែនាំឲ្យជីវិតរបស់យើងទៅមុខបាន។ ដោយសារព្រះយេស៊ូយើងជួបជុំគ្នា ដោយសារព្រះយេស៊ូយើងអាចដឹកនាំគ្រប់សកម្មភាពដែលយើងធ្វើពីមួយថ្ងៃទៅមួយថ្ងៃ។ ទាំងការសិក្សា ទាំងសិប្បកម្ម ទាំងអភិវឌ្ឍជនបទទាំងកសិកម្ម ទាំងទទួលអ្នកអស់សង្ឃឹមនៅក្នុងជីវិត យើងអាចធ្វើបាន ដោយសារយើងមានព្រះយេស៊ូដែលប្រមូលយើង ដែលផ្តល់កម្លាំងឲ្យយើង ដែលណែនាំឲ្យយើងទៅជាមហាគ្រួសារ។ មហាគ្រួសារដំបូងបំផុត គឺមានហោរាចារ្យ អ្នកគង្វាល ប្រជាជន ទេវទូត ព្រះនាងម៉ារី លោកយ៉ូសែប និងព្រះឱរស្តយេស៊ូ។ មានទាំងអ្នកមាន អ្នកក្រីក្រ អ្នកដែលសង្គមរើសអើង យើងអាចរួមគ្នាជាមហាគ្រួសារដ៏សុខសាន្ត ដើម្បីបង្ហាញថាបង្ហាញអំណរសប្បាយឲ្យគ្នាទៅវិញទៅមក។

ចាប់ពីថ្ងៃនេះតទៅរោងព្រះយេស៊ូប្រសូត លែងជារូបចម្លាក់ដែលយើងដាក់នៅក្នុងរោង តែជាជីវិតរបស់យើងផ្ទាល់។ ដើម្បីទទួលស្វាគមន៍ទាំងព្រះយេស៊ូ ទាំងព្រះនាងម៉ារី ទាំងលោកយ៉ូសែប ទាំងទេវទូត ទាំងហោរាចារ្យ ទាំងអ្នកគង្វាល ទាំងប្រជាជន ដើម្បីឲ្យយើងបង្កើតក្រុមគ្រួសារយ៉ាងធំ ដែលចេញពីកម្លាំងរបស់យើង ពីដួងចិត្តរបស់យើង។ ពិតមែនយើងជាមហាគ្រួសារ ដែលសាងសងមហារោងព្រះយេស៊ូប្រសូត ដើម្បីណែនាំឲ្យមនុស្សទាំងអស់អាចមកថ្វាយបង្គំព្រះឱរស្គយេស៊ូបាន។ យប់នៅក្នុងអំណរសប្បាយ យើងកោតសរសើរព្រះជាម្ចាស់ និងអរព្រះគុណព្រះអង្គរួមជាមួយទេវទូតទាំងឡាយ យើងច្រៀងកោតសរសើរឲ្យមនុស្សទាំងអស់ទទួលបានសេចក្តីសុខសាន្ត ពិតមែនព្រះយេស៊ូប្រសូតហើយ។ អាម៉ែន៕